ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤០០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការដឹកនាំការអនុវត្តគម្រោង ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកទេសវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤២៨ សហវ.ប្រក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្តាល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់។

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការដឹកនាំការអនុវត្តគម្រោងប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងជំរុញការអនុវត្តលក្ខខណ្ឌបង្គង់ ចាប់តាំងពីដំណាក់កាលបរិច្ឆេទផ្តាច់មុខ (Exclusivity Date) និងកាតព្វកិច្ចផ្សេងទៀតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រហូតដល់ការសម្រេចបាននូវហិរញ្ញប្បទានសម្រាប់គម្រោង (Financial Close) និងការដាក់ឱ្យប្រតិបត្តិការ និងថែទាំគម្រោង ដូចមានចែងក្នុងកិច្ចសន្យាសម្បទាននៃការអនុវត្តគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ។ ។

**ប្រការ២.-**

គណៈកម្មាធិការនេះ មានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| ១- ឯកឧត្តម **ហែម ចណ្ណាឌី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | អនុប្រធាន |
| ៣- តំណាងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | អនុប្រធាន |
| ៤- តំណាងអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៥- តំណាងអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦- តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៧- តំណាងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៨- តំណាងអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល | លេខាធិការ។ |

**ប្រការ៣.-**

គណៈកម្មាធិការនេះ មានភារកិច្ច ដូចតទៅ÷

- សម្របសម្រួល ជំរុញ និងតាមដានការអនុវត្តលក្ខខណ្ឌបង្គង់ និងកាតព្វកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដូចមានចែងក្នុងកិច្ចសន្យាសម្បទានគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ។
- សម្របសម្រួល និងតាមដានការធ្វើកិច្ចលទ្ធកម្មដី និងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។
- ពិនិត្យ និងតាមដានការអនុវត្តគម្រោង គ្រប់ដំណាក់កាល ចាប់តាំងពីដំណាក់កាលសាងសង់ រហូតដល់ដំណាក់កាលប្រគល់ទ្រព្យសម្បត្តិគម្រោងជូនរដ្ឋវិញ ក្រោយរយៈពេលសម្បទានត្រូវបានបញ្ចប់។
- រាយការណ៍ ផ្តល់យោបល់ និងរៀបចំយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច។

**ប្រការ៤.-**

គណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំគណៈកម្មាធិការនេះ តាមការប្រគល់សិទ្ធិរបស់ប្រធាន។

គណៈកម្មាធិការនេះ មានរបបប្រជុំសាមញ្ញ ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំជាវិសាមញ្ញ តាមការចាំបាច់។

គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការងាររបស់ខ្លួន។

**ប្រការ៥.-**

គណៈកម្មាធិការនេះ អាចស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីគ្រប់អគ្គនាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងផ្តល់យោបល់លើការពិនិត្យ និងអនុវត្តគម្រោងផ្លូវល្បឿនលឿនរាជធានីភ្នំពេញ-ខេត្តព្រះសីហនុ។

**ប្រការ៦.–**

នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ៧ ស. ៩ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១៨

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ